Department of Public Works
411 West Ocean Blvd., 5th Floor
Long Beach, CA 90802

CITY OF LONG BEACH

# សាលាក្រុងឡុងប៊ិច រដ្ឋកាលីហ្វ័រញ៉ា
# សេចក្តីណែនាំអំពីការលើកស្លាកសម្រាប់កន្លែងចតយានយន្តជនពិការនៅតាមដងផ្លូវ

សេចក្តីណែនាំនេះ មានគោលបំណងពន្យល់ជូនបងប្អូនពលរដ្ឋក្រុងឡុងប៊ិច អំពីដំណើរការដាក់ពាក្យសុំលើកស្លាកសម្រាប់កន្លែងចតយានយន្តជនពិការនៅតាមដងផ្លូវ នៅផ្លូវសិទ្ធិអាទិភាពរបស់សាធារណជនទូទៅ នៅក្នុងទីក្រុងឡុងប៊ិច ដោយអនុលោមតាមក្រមស្តីពីយានជំនិះរបស់រដ្ឋកាលីហ្វ័រញ៉ា (CVC) §21458(a)(5) និង LBMC Ch.10.34។

## ក) ជម្រើសក្នុងពេលឥឡូវ សម្រាប់ចតយានយន្តជនពិការ

ជនពិការគ្រប់រូប ឬជនពិការជាអតីតយុទ្ធជន ដែលមានបង្ហាញស្លាកចតយានយន្តជនពិការ ឬស្លាកជនពិការ **ត្រូវបានអនុញ្ញាតឲ្យចតយានយន្តនៅលើដងផ្លូវទាំងអស់ ដែលមានស្លាកកំណត់សម្រាប់ជនពិការ** [រាល់សេចក្តីយោងគប្បីផ្តោតលើសំណេរ **“កន្លែងចតយានយន្តជនពិការនៅតាមដងផ្លូវ” ដែលមានសម្គាល់គំនូសពណ៌ខៀវលើគែមផ្លូវ និងស្លាកពណ៌ខៀវ**]។

## ខ) លក្ខខណ្ឌដើម្បីអាចលើកស្លាកនោះបាន

កន្លែងចតយានយន្តជនពិការនៅតាមដងផ្លូវនេះ ត្រូវតែកំណត់ដោយយោងលើការបង្ហាញអំពីតម្រូវការចាំបាច់ ដែលមានតែមន្ត្រីវិស្វករផ្នែកចរាចរណ៍ក្រុងជាអ្នកសម្រេច។ ក្នុងការសម្រេចអំពីតម្រូវការចាំបាច់នេះ មន្ត្រីវិស្វករនោះនឹងពិចារណាមើលលក្ខខណ្ឌដូចខាងក្រោម៖

- អ្នកដាក់ពាក្យសុំ ដែលត្រូវតែជាពលរដ្ឋរស់នៅជាប់លាប់នៅអាសយដ្ឋាន ក្នុងក្រុងឡុងប៊ិច ទើបអាចដាក់ពាក្យសុំកន្លែងចតយានយន្តជនពិការនៅតាមដងផ្លូវនេះបាន។ លក្ខខណ្ឌតម្រូវសម្រាប់ឯកសារបញ្ជាក់ការរស់នៅក្នុងក្រុងឡុងប៊ិចនេះ គឺទាល់តែមានប័ណ្ណបើកបរ ឬវិក្កយបត្របង់ទឹកភ្លើង។

- អ្នកដាក់ពាក្យសុំត្រូវតែមានប័ណ្ណ ឬស្លាកសម្រាប់ចតយានយន្តជនពិការជា**អចិន្ត្រៃយ៍** ដែលចេញដោយនាយកដ្ឋានយានយន្តរដ្ឋកាលីហ្វ័រញ៉ា។ ស្លាកជនពិការបណ្តោះអាសន្នមិនត្រូវនឹងលក្ខខណ្ឌនេះនោះទេ។

- សម្រាប់ផ្ទះល្វែង អគារខុនដូ និងផ្ទះថោនហូមស៍ គឺត្រូវតែប្រើប្រាស់ឲ្យអស់ពីលទ្ធភាពសម្រាប់ការចតយាន្តជនពិការនៅទីនោះជាមុនសិន។ យើងសូមជំរុញឲ្យអ្នកដាក់ពាក្យសុំ ទាក់ទងទៅខាងគ្រប់គ្រងអគារ ឬសមាគមអគារស្នាក់នៅនោះ ដើម្បីសួររកកន្លែងសម្រាប់ចតយានយន្តជនពិការ នៅបរិវេណនោះសិន។

- សម្រាប់អ្នករស់នៅក្នុងផ្ទះមួយគ្រួសារដាច់ពីគេ គឺទាល់តែកន្លែងចតយានយន្តដែលនៅផុតពីផ្លូវ គឺរកមិនបាន ឬចូលចតមិនកើត។ ឧទាហរណ៍នៃការចូលចតមិនបាន៖
    - ♦ រោងចតយានយន្ត មានទំហំតូចជាងទទឹង ១៤ហ្វីត។

## គ) វិស្វកម្ម និងការសិក្សាអំពីលទ្ធភាពចត

នៅមុនឯកភាពចេញស្លាក សម្រាប់កន្លែងចតយានយន្តជនពិការនៅតាមដងផ្លូវនេះ បុគ្គលិកនៃការិយាល័យចលនាដឹកជញ្ជូន នឹងចុះសិក្សាអំពីលទ្ធភាពនៃការចតនេះ។ ការចុះសិក្សានេះ តម្រូវដូចខាងក្រោម៖

- ការយល់ព្រមពីអ្នកដាក់ពាក្យ ដើម្បីអនុញ្ញាតឲ្យមន្ត្រីការិយាល័យចលនាដឹកជញ្ជូន ចេញចូលកន្លែងរស់នៅរបស់អ្នកដាក់ពាក្យ ដើម្បីបញ្ជាក់ក្រែងមានកន្លែងចតផុតពីផ្លូវ និងដើម្បីអនុញ្ញាតឲ្យមន្ត្រីនោះចូលទៅមើលរោងចតយានយន្តរបស់អ្នកដាក់ពាក្យផង។ **អ្នកដាក់ពាក្យសុំ ដែលយករោងចតយានយន្ត ទៅធ្វើជាកន្លែងស្តុកទុករបស់របរផ្សេងៗ នឹងទទួលបានការបដិសេធ ដោយមិនអាចលើកស្លាកកន្លែងចតយានយន្តជនពិការនៅតាមដងផ្លូវនេះ បានឡើយ។**

- ដើម្បីទទួលបានការអនុញ្ញាតឲ្យលើកស្លាកកន្លែងចតយានយន្តជនពិការនៅតាមដងផ្លូវនេះបាន គឺទាល់តែគែមផ្លូវនោះ មានបរិវេណបណ្តោយ ២០ហ្វីត សម្រាប់ចតយានយន្តបណ្តោយផ្លូវ និង ១០ហ្វីត សម្រាប់ចត់យានយន្តបញ្ឆិតបែបចំណិតត្រសក់។

## ឃ) ការដោះស្លាកកន្លែងចតយានយន្តជនពិការនៅតាមដងផ្លូវចេញវិញ

វិស្វករចរាចរណ៍ក្រុង អាចពិនិត្យសើរើ និងវាយតម្លៃឡើងវិញ ចំពោះកន្លែងចតយានយន្តជនពិការនៅតាមដងផ្លូវនេះ។ មានកាលៈទេសៈជាច្រើន ដែលតម្រូវឲ្យដោះស្លាកកន្លែងចតយានយន្តជនពិការ នៅតាមដងផ្លូវនោះចេញវិញ រួមមាន៖

- លែងត្រូវការកន្លែងចតនោះតទៅទៀត
- ជនពិការរូបនោះបានផ្លាស់ទីលំនៅទៅកន្លែងផ្សេង ដោយបោះបង់ចោលកន្លែងចតនោះ ឬបានទទួលមរណភាព។
- កន្លែងចតនោះត្រូវបានលួចកែ ដើម្បីប្រើខុសគោលដៅ។
- លក្ខខណ្ឌផ្សេងៗបានផ្លាស់ប្តូរ ដូចជាថាជនពិការរូបនោះ លែងគ្រប់លក្ខខណ្ឌសម្រាប់ទទួលបានប័ណ្ណ/ស្លាកចតយានយន្តជនពិការ។

## ង) ការព្រមព្រៀងទៅនឹងលក្ខខណ្ឌតម្រូវ សម្រាប់ការដាក់ពាក្យសុំកន្លែងចតយានយន្តជនពិការនៅតាមដងផ្លូវ

ក្រោយពីបានអានសេចក្តីណែនាំរបស់សាលាក្រុង អំពីកន្លែងចតយានយន្តជនពិការនៅតាមដងផ្លូវ អ្នកដាក់ពាក្យសុំនឹងត្រូវបំពេញពាក្យសុំ រួចហើយចុះហត្ថលេខាលើកិច្ចព្រមព្រៀង/ទម្រង់នៃការលះបង់សិទ្ធិប្តឹង។ កាលណាចុះហត្ថលេខាលើពាក្យសុំនេះ មានន័យថាអ្នកដាក់ពាក្យសុំ ទទួលស្គាល់ និងយល់ព្រមទៅតាមលក្ខខណ្ឌតម្រូវទាំងអស់ ដែលពាក់ព័ន្ធនឹងការលើកស្លាកកន្លែងចតយានយន្តជនពិការនៅតាមដងផ្លូវនេះ។

Department of Public Works
411 West Ocean Blvd., 5th Floor
Long Beach, CA 90802

CITY OF LONG BEACH

# សាលាក្រុងឡុងប៊ិច
# ពាក្យសុំលើកស្លាកសម្រាប់កន្លែងចតយានយន្តជនពិការនៅតាមដងផ្លូវ

## ក្នុងតំបន់ភូមិអ្នកស្រុករស់នៅ

ពាក្យសុំដែលដាក់មក នឹងត្រូវពិនិត្យមើលតាមករណីជាក់ស្តែងនីមួយៗ។ រាល់កន្លែងចតយានយន្តជនពិការនៅតាមដងផ្លូវដែលមាន គឺសម្រាប់យានយន្តទាំងអស់ ដែលមានដាក់បង្ហាញស្លាកលេខសម្រាប់ចតយានយន្តជនពិការដែលមានសុពលភាព ឬស្លាកជនពិការដែលចេញដោយនាយកដ្ឋានយានយន្តនៃរដ្ឋកាលីហ្វ័រញ៉ា (DMV)។ រាល់បទប្បញ្ញត្តិដែលមានចែងនៅក្នុងក្រមយានយន្តនៃរដ្ឋកាលីហ្វ័រញ៉ា (CVC) និងក្រមសាលាក្រុងឡុងប៊ិច គឺត្រូវអនុវត្តជាធរមាននៅតាមទីតាំងទាំងនោះ។

**សូមដាក់ពាក្យសុំដែលបានបំពេញរួចទៅ៖**

City of Long Beach
Transportation Mobility Bureau
411 West Ocean Blvd., 4th Floor
Long Beach, CA  90802

**ក)     ព័ត៌មានរបស់អ្នកដាក់ពាក្យសុំ**

នាម និងគោត្តនាម៖ ______________________________

អាសយដ្ឋាន៖ ______________________________

ទូរស័ព្ទ៖ ______________ អ៊ីម៉េល៖ ______________

លេខប័ណ្ណបើកបរនៅរដ្ឋកាលីហ្វ័រញ៉ា៖ ______________ ផុតសុពលភាព៖ ___/___/____

**ខ)     ព័ត៌មានអំពីម្ចាស់ផ្ទះ (ម្ចាស់អគារខុនដូត្រូវមានការយល់ព្រមពី HOA សម្រាប់តំឡើង)**

នាម និងគោត្តនាម៖ ______________________________

អាសយដ្ឋាន៖ ______________________________

ទូរស័ព្ទ៖ ______________ អ៊ីម៉េល៖ ______________

**គ)     ព័ត៌មានអំពីកន្លែងចតយានយន្តជនពិការ**

ទីតាំងដែលស្នើសុំដាក់គែមផ្លូវពណ៌ខៀវ៖ ______________________________

______________________________

មូលហេតុដែលស្នើសុំ៖

______________________________

______________________________

______________________________

១) តើនៅផ្ទះដែលពាក់ព័ន្ធនឹងការដាក់ស្នើសុំនេះ មានកន្លែងចតយានយន្តផុតពីផ្លូវដែរឬទេ?

- ____ បាទ/ចាស ____ ទេ

២) តើនៅចម្ងាយ ១៥០ហ្វីតពីផ្ទះដែលពាក់ព័ន្ធនឹងការដាក់ពាក្យសុំនេះ មានកន្លែងសម្រាប់ចតយានយន្តជនពិការតាមដងផ្លូវមួយរួចហើយមែនឬទេ?

- ____ បាទ/ចាស ____ ទេ

៣) បើកន្លែងចតយានយន្តជនពិការផុតពីផ្លូវមានស្រាប់ តើហេតុអ្វីបានជាត្រូវការកន្លែងចតយានយន្តជនពិការតាមដងផ្លូវ?

______________________________________________________________

______________________________________________________________

**ឃ) បើដាក់ពាក្យសុំដោយអ្នកមើលថែជនពិការ-ប្តី/ប្រពន្ធឬកូនរបស់ជនពិការដែលជាមនុស្សពេញវ័យ**

នាម និងគោត្តនាម៖ ______________________________________________

អាសយដ្ឋាន៖ ______________________________________________

ទូរស័ព្ទ៖ ____________________ អ៊ីម៉េល៖ ______________________________

លេខប័ណ្ណបើកបរនៅរដ្ឋកាលីហ្វ័រញ៉ា៖ __________________ ផុតសុពលភាព៖ ___/___/____

សូមពន្យល់ថាតើហេតុអ្វីបានជាអ្នកដាក់ពាក្យសុំ ដែលពុំមានប័ណ្ណ/ស្លាកជនពិការ តម្រូវឲ្យអ្នកបើកបររបស់គាត់ ដែលពុំមានប័ណ្ណ/ស្លាកជនពិការចេញដោយ DMV បង្ហាញមូលហេតុក្នុងការសុំលើកស្លាកកន្លែងចតយានយន្តជនពិការតាមដងផ្លូវនោះ។

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

មតិបន្ថែម៖

______________________________________________

______________________________________________

______________________________________________

## ង)  ឯកសារគាំទ្រ

សូមភ្ជាប់មកជាមួយនូវឯកសារថតចម្លងដូចខាងក្រោម។ ហាមផ្ញើឯកសារដើម។

- ❑ ឯកសារបញ្ជាក់អាសយដ្ឋានរបស់អ្នកដាក់ពាក្យ (ភ្ជាប់វិក្កយបត្របង់ទឹកភ្លើងថ្មីៗ កិច្ចសន្យាជួលផ្ទះ ឬប័ណ្ណបើកបរ)
- ❑ ឯកសារបញ្ជាក់អំពីប័ណ្ណ/ស្លាកចតយានយន្តជនពិការចេញដោយ DMV (ភ្ជាប់ឯកសារថតចម្លងនៃលិខិតចុះបញ្ជីយានយន្ត ឬបង្កាន់ដៃប័ណ្ណជនពិការ)។ យើងមិនទទួលយកឯកសារថតចម្លងនៃប័ណ្ណ ឬស្លាកជនពិការនោះឡើយ។
- ❑ កិច្ចព្រមព្រៀង/លិខិតលះបង់សិទ្ធិប្តឹង សម្រាប់ការលើកស្លាកនេះ ដែលបំពេញចប់សព្វគ្រប់ និងមានចុះហត្ថលេខារួច។

**អាស្រ័យហេតុនេះ ខ្ញុំសូមបញ្ជាក់ ថាព័ត៍មានខ្ញុំបានផ្តល់ជូននេះ គឺពិត និងត្រឹមត្រូវ។**

ហត្ថលេខាអ្នកដាក់ពាក្យ៖ ______________________________  កាលបរិច្ឆេទ៖ ____________

សម្រាប់ព័ត៍មានបន្ថែម សូមបងប្អូនទាក់ទងទៅការិយាល័យចលនាដឹកជញ្ជូន
តាមលេខនេះ៖ (562) 570-6331

Department of Public Works
411 West Ocean Blvd., 5th Floor
Long Beach, CA 90802

CITY OF LONG BEACH

# សាលាក្រុងឡុងប៊ិច
# កិច្ចព្រមព្រៀងទៅតាមលក្ខខណ្ឌតម្រូវ សម្រាប់លើកស្លាកកន្លែងចតយានយន្ត ជនពិការតាមដងផ្លូវ

អ្នកដាក់ពាក្យសុំកន្លែងចតយានយន្តជនពិការតាមដងផ្លូវ ត្រូវតែយល់ស្រប និងត្រូវអនុវត្តតាមលក្ខខណ្ឌតម្រូវដូចខាងក្រោម៖

១) អ្នកដាក់ពាក្យសុំទទួលស្គាល់ថា ការបំពេញពាក្យសុំនេះ គឺមិនមែនបានន័យថាដឹងតែបានកន្លែងចតយានយន្តជនពិការតាមដងផ្លូវនោះទេ។

២) ពាក្យសុំនេះ គឺផ្តល់ជូនសម្រាប់តែរយៈពេលពីរឆ្នាំម្តងប៉ុណ្ណោះ។ ផុតពីនោះ ត្រូវដាក់ពាក្យសុំបន្ត និងត្រូវដាក់ឯកសារគាំទ្រ សម្រាប់ការប្រើប្រាស់កន្លែងនោះបន្តទៀត។ អ្នកដាក់ពាក្យសុំត្រូវតែសង្កេត និងគោរពតាមរាល់បទប្បញ្ញត្តិ អំពីការចតយានយន្ត ដែលមានចែងក្នុងក្រមសាលាក្រុងឡុងប៊ិច ត្រង់ជំពូកទី 10.40 *et.seq.*។

៣) កន្លែងចតយានយន្តជនពិការតាមដងផ្លូវនេះ នឹងមិនត្រូវប្រើប្រាស់សម្រាប់ការចតយានយន្តទុកចោលរយៈពេលយូរអង្វែងនោះឡើយ។ យានយន្តត្រូវតែមានការថែទាំ និងជួលជុលឲ្យបានល្អ និងត្រូវដំណើរការ ដូចមានកំណត់ក្នុងក្រមស្តីពីយានយន្តរបស់រដ្ឋកាលីហ្វ័រញ៉ា។ សម្រាប់គោលបំណងនៃគោលនយោបាយនេះ រាល់យានយន្តដែលចតទុកចោលរយៈពេលយូរអង្វែង នឹងត្រូវកំណត់ថាជាយានយន្តចតចោល ឬទុកចោលនៅលើដងផ្លូវសាធារណៈនៅមួយកន្លែង និងអត់មានបើកបរចេញទៅណា ឬអត់មានចលនាលើពីរយៈពេល ៧២ម៉ោង។

៤) ការប្រើប្រាស់កន្លែងចតសម្រាប់ជនពិការតាមដងផ្លូវនេះ បើប្រើខុសគោលដៅ គឺនឹងត្រូវដកស្លាកនោះចេញវិញ។ ការប្រើប្រាស់ខុសគោលដៅនេះ នឹងត្រូវសម្រេចដោយវិស្វករចរាចរណ៍ក្រុង។ ក្នុងការសម្រេច ថាតើកន្លែងចតយានយន្តជនពិការណាមួយ ត្រូវបានប្រើខុសគោលដៅ វិស្វករចរាចរណ៍ក្រុងនឹងត្រូវពិចារណាលើកត្តាដូចខាងក្រោម៖
   - ក) ថេរៈវេលាដែលអ្នកដាក់ពាក្យសុំ បានទុកយានយន្តចោលនៅទីតាំងនោះ ដោយមិនបានដំណើរការវា។
   - ខ) ការប្រើប្រាស់ប័ណ្ណ ឬស្លាកលេខជនពិការរបស់សាមីខ្លួន ដោយខុសគោដៅ។
   - គ) អ្នកដាក់ពាក្យសុំបំពានក្រមណាមួយរបស់សាលាក្រុងឡុងប៊ិច ដូចមានចែងត្រង់ 10.40 *et seq* ឬបំពានគោលនយោបាយនេះ។
   - ឃ) កត្តាណាមួយផ្សេងទៀត ដែលវិស្វករចរាចរណ៍ក្រុង យល់ឃើញថាមានហេតុផលសមល្មម និងពាក់ព័ន្ធនឹងបញ្ហានោះ។

៥) កន្លែងចតយានយន្តជនពិការតាមដងផ្លូវ មិនមែនជាកន្លែងឯកជន ឬកន្លែងបម្រុងទុកសម្រាប់នរណាម្នាក់ដាច់ដោយឡែកនោះឡើយ។ កន្លែងនោះអាចប្រើប្រាស់បានសម្រាប់យានយន្តដទៃទៀត ដែលមានប័ណ្ណចតយានយន្តជនពិការ ដោយអនុវត្តតាមគោលការណ៍អ្នកមកមុនចតមុន។

៦) អាជ្ញាធរមានសមត្ថកិច្ច នឹងពង្រឹងច្បាប់ស្តីពីការចតយានយន្តនេះ។ នោះជាការទទួលខុសត្រូវរបស់ផ្នែកពង្រឹងការអនុវត្តច្បាប់ ស្តីពីការចតយានយន្តនៃនាយកដ្ឋានសាធារណការ និងនាយកដ្ឋានប៉ូលិសក្រុងឡុងប៊ិច។

ខ្ញុំជាអ្នកដាក់ពាក្យ បានអាននិងយល់អំពីកិច្ចព្រមព្រៀង ស្តីពីលក្ខខណ្ឌតម្រូវសម្រាប់ការលើកស្លាកកន្លែងចតយានយន្តជនពិការតាមដងផ្លូវ លើផ្លូវសាធារណៈ និងយល់ព្រមអនុវត្តតាម។

ឈ្មោះ៖ __________________ ហត្ថលេខា៖__________________ កាលបរិច្ឆេទ៖________

អាសយដ្ឋាន៖____________________________________________________________

Department of Public Works
411 West Ocean Blvd., 5th Floor
Long Beach, CA 90802

CITY OF LONG BEACH

# សាលាក្រុងឡុងប៊ិច
# កន្លែងចតយានយន្តជនពិការតាមដងផ្លូវសាធារណៈ
# លិខិតលះបង់សិទ្ធិប្តឹងរឿងទទួលខុសត្រូវ និងការលះបង់សិទ្ធិទាមទារសំណងទូទៅ

កម្មវិធីកន្លែងចតយានយន្តជនពិការតាមដងផ្លូវ(“កម្មវិធី”)នេះ គឺជាកម្មវិធីស្ម័គ្រចិត្តដោយឥតបង្ខិតបង្ខំ ដែលផ្តល់ជូនដោយសាលាក្រុងឡុងប៊ិច (“សាលាក្រុង”)។

ខ្ញុំ______________________________ តទៅនេះទទួលស្គាល់ថា ខ្ញុំចូលរួមក្នុងកម្មវិធីនេះដោយស្ម័គ្រចិត្តឥតមានការបង្ខិតបង្ខំ។ អាស្រ័យហេតុនេះ ខ្ញុំត្រូវទទួលខុសត្រូវទាំងស្រុងចំពោះរាល់ហានិភ័យនៃការរងរបួស ឬបាត់បង់ រួមទាំងមរណភាពផង ដែលអាចកើតចេញពីមការចូលរួមក្នុងកម្មវិធីនេះ។ ដូច្នេះខ្ញុំយល់ព្រមលះបង់សិទ្ធិក្នុងការប្តឹងសាលាក្រុង ឬមន្ត្រីសាលាក្រុង ភ្នាក់ងារ និង/ឬមន្ត្រីទាំងអស់ ដោយខ្ញុំមិនប្តឹងពួកគាត់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់ ពាក់ព័ន្ធនឹងការទាមទារសំណង ឬការសងថ្លៃខូចខាតណាមួយ ដែលអាចកើតមានលើរូបខ្ញុំ ដោយសារគ្រោះថ្នាក់ ជំងឺ របួស មរណភាព ការខូតខាត ការបាត់បង់ ឬការប្រើខុសគោលដៅណាមួយ ដែលកើតចេញដោយផ្ទាល់ ឬដោយប្រយោលពីការចូលរួមរបស់ខ្ញុំនៅក្នុងកម្មវិធីនេះ និងបញ្ហាដែលកើតឡើងក្នុងអំឡុងពេលដែលកំពុងចូលរួមកម្មវិធី ឬពេលណាមួយនៅក្រោយការចូលរួមកម្មវិធីនេះ។

ការលះបង់សិទ្ធិប្តឹងឲ្យទទួលខុសត្រូវ និងការលះបង់សិទ្ធិប្តឹងទាមទាមសំណងទូទៅនេះ គឺត្រូវអនុវត្តចំពោះករណីមិនថាការបាត់បង់ ការរងរបួស មរណភាព ការខូតខាត ឬការប្រើខុសគោលដៅ ឬអាចកើតមានដោយសារតែអំពើ ឬការធ្វេសប្រហែសរបស់សាលាក្រុង ឬភាគីដទៃទៀត និងការមិនយកចិត្តទុកដាក់ ឬអ្វីផ្សេងទៀតដែលពាក់ព័ន្ធនឹងការចូលរួមក្នុងកម្មវិធីនេះ នោះឡើយ។ ការលះបង់សិទ្ធិប្តឹងឲ្យទទួលខុសត្រូវ និងការលះបង់សិទ្ធិប្តឹងទាមទាមសំណងទូទៅនេះ គឺជាការទទួលខុសត្រូវរបស់ខ្ញុំ ទាយាទរបស់ខ្ញុំ អ្នកអនុវត្ត អ្នកមើលការខុសត្រូវ និងអ្នកតំណាងរបស់ខ្ញុំ។

ខ្ញុំសូមបញ្ជាក់ថា ព័ត៍មានដែលខ្ញុំបានផ្តល់ជូននេះ គឺពិត និងត្រឹមត្រូវ។

ឈ្មោះ៖ ________________________________________

ហត្ថលេខា៖ ________________________________________

លេខផ្លូវអាសយដ្ឋាន៖ ________________________________________

កាលបរិច្ឆេទ៖ ________________